**សម្ព័ន្ធសហគ្រាស**
**កៅស៊ូ វៀតណាម**
លេខ៖ ៣១៤/QD-HDTVCSVN

**សាធារណរដ្ឋសង្គមនិយម វៀតណាម**
**ឯករាជ្យ សេរីភាព សុភមង្គល**
*ទីក្រុង **ហូ ជីមិញ** ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០១៤*

(ការបកប្រែពីភាសា វៀតណាម)

# សេចក្តីសំរេច

**ស្តីពី៖** ការប្រកាសដាក់អោយអនុវត្តបទបញ្ញាលើការទទួល និងដោះស្រាយពាល់សំណើ ឬ ការតវ៉ា និងការផ្តល់ពត៌មានដល់បុគ្គល និងអង្គការនានា ចំពោះបញ្ហាទាំងឡាយដែលមានការពាក់ព័ន្ធជាមួយនឹងបណ្តាគំរោងអភិវឌ្ឍន៍កៅស៊ូ របស់ VRG នៅប្រទេស កម្ពុជា និង ឡាវ

## ក្រុមប្រឹក្សាសមាជិកសម្ព័ន្ធសហគ្រាសកៅស៊ូ វៀតណាម

- យោងតាមសេចក្តីសំរេចលេខ ២៤៩/២០០៦/QD-TTg ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ២០០៦ របស់នាយករដ្ឋមន្ត្រីរដ្ឋាភិបាល ស្តីពីការបង្កើតក្រុមហ៊ុនមេ-សម្ព័ន្ធសហគ្រាសកៅស៊ូ វៀតណាម
- យោងតាមអនុក្រិត្យលេខ ២៨/២០១៤/ND-CP ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ២០១៤ របស់រដ្ឋាភិបាល ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃសម្ព័ន្ធសហគ្រាសកៅស៊ូ វៀតណាម
- តាមសំណើសុំលេខ ២០៣៩/TTr-CSVN ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០១៤ របស់លោកអគ្គនាយកសម្ព័ន្ធសហគ្រាសកៅស៊ូ វៀតណាម

## សំរេច

**ប្រការ១៖** សំរេចដាក់អោយប្រើដោយភ្ជាប់នឹងសេចក្តីសំរេចនេះ "បទបញ្ញាលើការទទួល និងដោះស្រាយពាល់សំណើ ឬ ការតវ៉ា និងការផ្តល់ពត៌មានដល់បុគ្គល និងអង្គការនានា ចំពោះបញ្ហាទាំងឡាយដែលមានការពាក់ព័ន្ធ ជាមួយនឹងបណ្តាគំរោងអភិវឌ្ឍន៍កៅស៊ូ របស់ VRG នៅប្រទេស កម្ពុជា និង ឡាវ" ។

**ប្រការ២៖** សេចក្តីសំរេចនេះមានសុពលភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ប្រការ៣៖** ក្រុមប្រឹក្សាសមាជិក គណៈអគ្គនាយក នាយខុទ្ទកាល័យ គណៈកម្មការ អភិវឌ្ឍន៍កៅស៊ូ ប្រចាំនៅប្រទេសកម្ពុជា ប្រទេសឡាវ និងបណ្តាអង្គភាពពាក់ព័ន្ធ នៃ សម្ព័ន្ធសហគ្រាសកៅស៊ូ វៀតណាម ទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ។

**ប្រធានក្រុមប្រឹក្សាសមាជិក**
(ហត្ថលេខានិងត្រា)

**VO SY LUC**

*កន្លែងទទួល៖*
- ដូចប្រការ៣
- ឯកសារ.កាលប្បវត្តិ

**សម្ព័ន្ធសហគ្រាស** **សាធារណរដ្ឋសង្គមនិយម វៀតណាម**

**កៅស៊ូ វៀតណាម** **ឯករាជ្យ សេរីភាព សុភមង្គល**

(ការបកប្រែពីភាសា វៀតណាម)

# បទបញ្ជា

**ស្តីពី៖** ការទទួល និងដោះស្រាយពាល់សំណើ ឬ ការតវ៉ា និងការផ្តល់ពត៌មាន ដល់បុគ្គល និងអង្គការ លើបញ្ហាទាំងឡាយដែលមានការពាក់ព័ន្ធជាមួយនឹង បណ្តាគំរោងអភិវឌ្ឍន៍កៅស៊ូ របស់ VRG នៅប្រទេស កម្ពុជា និងប្រទេសឡាវ

(ដោយយោងទៅតាមសេចក្តីសំរេចលេខ ៣១៤/QD-HDTVCSVN

ចុះថ្ងៃ ១៦ ខែកក្កដា ឆ្នាំ២០១៤ របស់សម្ព័ន្ធសហគ្រាសកៅស៊ូ វៀតណាម)

## I- បទបញ្ញត្តិទូទៅ

### ប្រការ១៖ កម្មវត្ថុ និងដែនអនុវត្ត

១. បទបញ្ជានេះកំណត់អំពីការទទួល និងការដោះស្រាយនូវពាល់សំណើ ឬការតវ៉ា និងការផ្តល់ពត៌មានដល់បុគ្គល និង អង្គការនានាលើបញ្ហាទាំងឡាយដែលមានការពាក់ព័ន្ធជាមួយនឹងបណ្តាគំរោងអភិវឌ្ឍន៍កៅស៊ូ របស់ VRG នៅប្រទេស កម្ពុជា និងប្រទេស ឡាវ។

២. បញ្ហាទាំងឡាយដែលមានការពាក់ព័ន្ធដល់គំរោងអភិវឌ្ឍន៍កៅស៊ូរបស់ VRG ត្រូវបានកំណត់ជាបញ្ហាក្នុងក្របខណ្ឌនៃគំរោងអភិវឌ្ឍន៍កៅស៊ូរបស់ VRG តែប៉ុណ្ណោះ និងជាបន្ទុកកាតព្វកិច្ច ជាផលប្រយោជន៍សំរាប់អ្នកវិនិយោគ ស្របទៅតាមខ្លឹមសារនៃកិច្ចសន្យាដែលបានចុះហត្ថលេខាជាមួយនឹង រដ្ឋាភិបាលជាម្ចាស់ផ្តល់ដីសម្បទានសេដ្ឋកិច្ច ដើម្បីរៀបចំដំណើរការអនុវត្តន៍គំរោងអភិវឌ្ឍន៍កៅស៊ូ ដោយគោរពទៅតាមបទបញ្ញត្តិ ច្បាប់ជាធរមាននៃប្រទេសដែលគំរោងនោះកំពុងដំណើរការ។ ជាអាទ៍៖

- ចំពោះប្រទេសកម្ពុជា៖ គឺច្បាប់ភូមិបាល ប្រកាសស្តីពីការគ្រប់គ្រងដីធ្លីរបស់រដ្ឋ ប្រកាសស្តីពីសម្បទានដីសេដ្ឋកិច្ច ច្បាប់ស្តីពីព្រៃឈើ និងច្បាប់ដែលកំណត់អំពីតំបន់ត្រូវរក្សាទុក។
- ចំពោះប្រទេសឡាវ៖ គឺច្បាប់ភូមិបាល ច្បាប់ស្តីពីព្រៃឈើ ច្បាប់វិនិយោគ ប្រកាសស្តីពីការជួល និងសម្បទានដីធ្លីរបស់រដ្ឋ ប្រកាសស្តីពីការអនុវត្តន៍ច្បាប់ភូមិបាល ប្រកាសស្តីពីការចេញសំណាង និងរៀបចំឡើងវិញទីតាំងលំនៅដ្ឋាននៃគំរោងអភិវឌ្ឍន៍។

៣. បទបញ្ជានេះត្រូវអនុវត្តចំពោះគ្រប់អង្គភាពជាសមាជិក VRG កំពុងធ្វើការវិនិយោគនៅប្រទេសកម្ពុជា និងឡាវ មានឈ្មោះក្នុងបញ្ជីរាយនាមនៃឧបសម្ព័ន្ធទី១ ភ្ជាប់មកជាមួយនឹងបទបញ្ជានេះ។

### ប្រការ២៖ ភាសាប្រើ និងការទាក់ទង

រាល់សំណើ ឬការតវ៉ាដល់ VRG អាចប្រើជាភាសានៃប្រទេសដែលអង្គភាពពាក់ព័ន្ធកំពុងដំណើរការ ឬ ភាសាវៀតណាម ឬ ភាសាអង់គ្លេស ដើម្បីបង្ហាញអោយបានច្បាស់លាស់រាល់សំណើ ឬការតវ៉ា និងត្រូវបញ្ជាក់អំពី ឈ្មោះ អាសយដ្ឋាន លេខទូរសព្ទ (ឬអាសយដ្ឋានប្រៃសណីយ៍ អ៊ីម៉ែល សំរាប់ទាក់ទងនៅពេលត្រូវការចាំបាច់) របស់បុគ្គល អង្គការ ដែលមានសំណើ ឬការតវ៉ា ដើម្បីងាយស្រួលធ្វើការឆ្លើយតបទៅវិញ។

**ប្រការ៣៖ ទំរង់នៃការដាក់សំណើ ឬ ការតវ៉ា និងទីកន្លែងទទួល**

១. ទំរង់នៃការដាក់សំណើ ឬ ការតវ៉ាគឺត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។ បុគ្គល ឬ អង្គការពាក់ព័ន្ធអាចបញ្ជូនលិខិតស្តីពីសំណើ ឬ ការតវ៉ារបស់ខ្លួនដល់ការិយាល័យតំណាង VRG តាមរយៈអាសយដ្ឋានដែលបានបញ្ជាក់ក្នុងចំណុចទី ៣ នៃប្រការនេះ។

២. ពតិមានសំរាប់ទាក់ទង ផ្តល់ដោយបុគ្គល ឬអង្គការពាក់ព័ន្ធ ត្រូវបំពេញចូលក្នុងប័ណ្ណទទួលពតិមានអោយបានច្បាស់លាស់ តាមគំរូដែលភ្ជាប់មកជាមួយឧបសម្ព័ន្ធទី២ នៃបទបញ្ជានេះ។ VRG មិនទទួលខុសត្រូវចំពោះការផ្តល់ពតិមានសំរាប់ទាក់ទងខុសបណ្តាលអោយ VRG ពុំអាចធ្វើការឆ្លើយតបទៅវិញបាននូវលទ្ធផលនៃការដោះស្រាយ។

៣. អាសយដ្ឋានទទួលសំណើ និង ការតវ៉ា៖

ក- នៅប្រទេសកម្ពុជា៖ លេខ ៩២ មហាវិថី ព្រះនរោត្តម ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ខ- នៅប្រទេសឡាវ៖ ផ្លូវ T4 ភូមិ Hongke Muong Xaysettha រដ្ឋធានី Viengchan

គ- ទីស្នាក់ការអង្គភាពជាសមាជិករបស់ VRG នៅក្នុងប្រទេសដែលអង្គភាពនោះកំពុងដំណើរការ។

៤. ការិយាល័យតំណាង VRG ឬ អង្គភាពជាសមាជិក VRG ពាក់ព័ន្ធនឹងផ្តល់បង្កាន់ដៃ ១ មានកត់លេខយោងអោយបុគ្គល ឬ អង្គការ នៅពេលទទួលបានឯកសារបញ្ជាក់អំពីសំណើ ឬ ការតវ៉ា។ បង្កាន់ដៃនេះអាចត្រូវបានផ្ញើដោយផ្ទាល់ ឬ ផ្ញើតាមរយៈប្រៃសណីយ៍ ស្របទៅតាមរូបភាពដែលឯកសារនោះបានបញ្ជូនមក។ គំរូបង្កាន់ដៃមានភ្ជាប់មកជាមួយក្នុងឧបសម្ព័ន្ធទី២។

**II. ការទទួល និងដំណោះស្រាយចំពោះសំណើ ឬ ការតវ៉ា និងការផ្សព្វផ្សាយនៃលទ្ធផលជាសាធារណៈ**

**ប្រការ៤៖ ការទទួលសំណើ ឬ ការតវ៉ា**

១. ការិយាល័យតំណាង VRG ប្រចាំនៅប្រទេសមានអង្គភាពពាក់ព័ន្ធ ក្នុងដែនសមត្ថកិច្ចនឹងចេញសេចក្តីសំរេច ឬ ដាក់ជូន VRG សំរេចប្រគល់អោយអង្គភាពពាក់ព័ន្ធធ្វើជាម្ចាស់ការ ឬត្រូវសហការជាមួយស្ថាប័នផ្សេងៗទៀតដើម្បីដោះស្រាយ។ ទន្ទឹមនិងនោះត្រូវចម្លងឯកសារ ជា

លទ្ធផលនៃកាដោះស្រាយជូនគណៈកម្មការអភិវឌ្ឍន៍កៅស៊ូ របស់ VRG ប្រចាំនៅប្រទេសដែលអង្គភាពពាក់ព័ន្ធកំពុងដំណើការ ដើម្បីធ្វើការតាមដាន និងដាស់តឿនក្នុងការអនុវត្តន៍។

២. ការិយាល័យតំណាង VRG ប្រចាំនៅប្រទេសមានអង្គភាពពាក់ព័ន្ធ ទទួលបន្ទុករៀបចំចាត់បុគ្គលិកទទួលសំណើ ឬ ការតវ៉ា និងធ្វើការណែនាំដល់បុគ្គល ឬ អង្គការពាក់ព័ន្ធនោះ ហើយត្រូវបើកបញ្ជីសំរាប់តាមដានការទទួលឯកសារទាំងនោះ រួចបញ្ជូនដល់អង្គភាពជាសមាជិករបស់ VRG ដែលមានការពាក់ព័ន្ធដើម្បីធ្វើការដោះស្រាយ ទន្ទឹមនឹងនេះត្រូវធ្វើការតាមដាន ត្រួតពិនិត្យ បូកសរុប រៀបចំរបាយការណ៍ស្តីពី លទ្ធផលនៃការដោះស្រាយអោយសមស្របតាមការកំណត់។

៣. VRG នឹងមិនធ្វើការឆ្លើយតប និងផ្តល់ពត៌មានក្នុងករណីណាមួយដូចខាងក្រោមនេះ ៖

ក. រាល់ពត៌មានដែលអជ្ញាធរ នៅប្រទេសដែលអង្គភាពពាក់ព័ន្ធកំពុងដំណើរការកំណត់អោយអ្នកវិនិយោគមិនត្រូវផ្តល់ពត៌មាន ប្រសិនបើគ្មានការអនុញ្ញាតពីស្ថាប័នមានសម្ថកិច្ចទេនោះ។

ខ. រាល់បញ្ហានៅក្រៅក្របខ័ណ្ឌ នៃសិទ្ធ ឬ កាតព្វកិច្ច ជាបន្ទុក របស់អ្នកវិនិយោគត្រូវគោរពតាម។

គ. រាល់លិខិតអនាមិក គ្មានពត៌មានបញ្ជាក់អំពី ទីកន្លែង និងអ្នកផ្ញើរ។

ឃ. រាល់សំណូមពរអោយផ្តល់ពត៌មាន ដែលគ្មានការពាក់ព័ន្ធដល់គំរោង ឬ ចំពោះសំណើរមានខ្លឹមសារដោយគោលបំណងមិនល្អ។

**ប្រការ៩៖ ការដោះស្រាយចំពោះសំណើ ឬ ការតវ៉ា នៅអង្គភាពពាក់ព័ន្ធ**

១. អង្គភាពពាក់ព័ន្ធទទួលបន្ទុកធ្វើការដោះស្រាយ និងរៀបចំរបាយការណ៍អំពីលទ្ធផលដាក់ជូនការិយាល័យ VRG ប្រចាំនៅប្រទេសដែលអង្គភាពនោះកំពុងដំណើរការ ដើម្បីឆ្លើយតបដល់បុគ្គល ឬ អង្គការមានសំណើ ឬ ការតវ៉ា។

២. ករណីទទួលបានសំណើ ឬ ការតវ៉ាមានខ្លឹមសារស្មុកស្មាញ ពាក់ព័ន្ធដល់អង្គភាពផ្សេងៗជាសមាជិករបស់ VRG ច្រើនគ្នានោះ ត្រូវការចាំបាច់ទុកពេលសំរាប់សហការគ្នា ធ្វើការត្រួតពិនិត្យ និង មានដំណោះស្រាយដោយឯកភាពជាមួយគ្នា។ ករណីនេះការិយាល័យតំណាងត្រូវប្រកាសជូនដំណឹងដល់ បុគ្គល ឬ អង្គការអោយបានជ្រាបនូវលទ្ធផលនៃការដោះស្រាយហើយត្រូវបញ្ជាក់អំពីពេលវេលាដែលត្រូវពន្យារដើម្បីឆ្លើយតបទៅនឹងសំណើ ឬ ការតវ៉ានោះ។

៣. ការិយាល័យតំណាង VRG ប្រចាំនៅប្រទេសមានអង្គភាពពាក់ព័ន្ធជាអ្នកទទួលបន្ទុក៖

ក. ធ្វើការតាមដាន ដាស់តឿន ត្រួតពិនិត្យលើការដោះស្រាយរាល់សំណើ ឬ ការតវ៉ាចំពោះអង្គភាពទាំងអស់ជាសមាជិករបស់ VRG។

ខ. រៀបចំរបាយការណ៍ដូចបានកំណត់ក្នុងប្រការ៧។

គ. ប្រកាសជូនដំណឹងអំពីលទ្ធផលនៃការដោះស្រាយដល់បុគ្គល ឬ អង្គការ ដែលមានសំណើ ឬការតវ៉ា ។

ង. រៀបចំរបាយការណ៍ដាក់ជូនគណៈអចិន្ត្រៃយ៍ នៃគណៈកម្មការអភិវឌ្ឍន៍កៅស៊ូ ដើម្បីមានវិធានការចាំបាច់ក្នុងការអនុវត្តន៍អោយបាន ត្រឹមត្រូវតាមបទបញ្ជាចំពោះដំណោះស្រាយលើរាល់សំណើ និង ការតវ៉ារបស់បុគ្គល ឬ អង្គការ។

**ប្រការ៦៖ ចម្លើយអំពីលទ្ធផលនៃការដោះស្រាយលើរាល់សំណើ ឬ ការតវ៉ា**

១- ការិយាល័យតំណាង VRG ប្រចាំនៅប្រទេសដែលមានអង្គភាពពាក់ព័ន្ធ នឹងធ្វើការឆ្លើយតបដល់បុគ្គល ឬ អង្គការមានសំណើ ឬ ការតវ៉ា ក្នុងរយៈពេលកំណត់គឺ ៣០ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានឯកសារបញ្ជាក់អំពីសំណើ ឬ ការតវ៉ានោះ។ ករណីមានភាពស្មុកស្មាញដូចបានរៀបរាប់ក្នុង ចំណុច ៥.២ ការិយាល័យតំណាង VRG ក្នុងអំឡុងពេល ៣០ថ្ងៃ នឹងផ្តល់ចម្លើយជាបណ្តោះអាសន្នដល់ បុគ្គល ឬ អង្គការពាក់ព័ន្ធ ដើម្បីជូនដំណឹងអំពីពត៌មាននៃការដោះស្រាយ និងបញ្ជាក់អពីកាលបរិច្ឆេទដែលគ្រោងនឹងផ្តល់ចម្លើយជាផ្លូវការ។

២. ករណីសំណើ ឬ ការតវ៉ាមានលក្ខណៈដូចបានរៀបរាប់ក្នុង ចំណុច ៤.៣ ការិយាល័យតំណាង VRG នឹងគ្មានបន្ទុកធ្វើការឆ្លើយតបទេ គ្រាល់តែជូនដំណឹងដើម្បីបកស្រាយនូវមូលហេតុដែលបណ្តាលអោយសំណូមពររបស់ពួកគាត់មិនត្រូវបានទទួលការឆ្លើយតបក្នុងអំឡុងពេល ៣០ថ្ងៃដូចបានកំណត់។ អាស្រ័យតាមករណីនិមួយៗ និងតាមលទ្ធភាព ការិយាល័យតំណាង VRG អាចធ្វើការណែនាំជួយដល់បុគ្គល ឬ អង្គការ ដើម្បីទាក់ទងដោយផ្ទាល់ជាមួយនឹងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីដាក់សំណើ ឬ ការតវ៉ា។

៣. រាល់ការឆ្លើយតបទាំងអស់ របស់ការិយាល័យតំណាង VRG ដល់បុគ្គល ឬ អង្គការ ត្រូវមានបញ្ជាក់អំពីលេខយោងដែលបានកត់លើបង្កាន់ដៃទទួលសំណើ ឬ ការតវ៉ា។

៤. លទ្ធផលនៃការដោះស្រាយចំពោះសំណើ ឬ ការតវ៉ា ត្រូវផ្សព្វផ្សាយតាមប្រព័ន្ធពត៌មានសាធារណៈ ឬ ត្រូវបិទផ្សាយ ក្នុងករណីសំណើ ឬ ការតវ៉ានោះមានលក្ខណៈជាតំណាង (បុគ្គល ឬ អង្គការ ជាច្រើនមានសំណើ ឬ ការតវ៉ារួមគ្នា)

**III. ការអនុវត្តន៍**

**ប្រការ៧៖ ការរៀបចំរបាយការណ៍**

មុនថ្ងៃទី ២០ ក្នុងខែបញ្ចប់ នៃត្រីមាសនិមួយៗជាកំណត់ គ្រប់អង្គភាពត្រូវរៀបចំរបាយការណ៍ស្តីពីការទទួល និងដំណោះស្រាយលើរាល់សំណើរ ឬ ការតវ៉ា ជូនការិយាល័តំណាង VRG ប្រចាំនៅប្រទេសដែលអង្គភាពរបស់ខ្លួនកំពុងដំណើរការ ដើម្បីធ្វើការបូកសរុបនិងរាយការណ៍ជូនមកគណៈអចិន្ត្រៃយ៍ នៃគណៈកម្មការអភិវឌ្ឍន៍កៅស៊ូ។

**ប្រការ៨៖ ការអនុវត្តន៍**

១. ការិយាល័យតំណាង VRG និងគ្រប់អង្គភាពជាសមាជិករបស់ VRG ដែលកំពុងធ្វើការវិនិយោគនៅប្រទេសកម្ពុជា និងប្រទេសឡាវ ទទួលបន្ទុកអនុវត្តបទបញ្ជានេះ។

២.ក្នុងអំឡុងពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃសេចក្តីសំរេចលេខ ៣១៤/QD-HDTVCSVN ចូលជាធរមាន ការិយាល័យតំណាង VRG និងគ្រប់អង្គភាពជាសមាជិករបស់ VRG ដែលកំពុងធ្វើការ

វិនិយោគនៅប្រទេសកម្ពុជា និងប្រទេសឡាវ ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនូវពត៌មានលំអិតនៃបទបញ្ជានេះ ដោយធ្វើការបិទផ្សាយនៅទីស្នាក់ការ និងជូនដំណឹងដល់អាជ្ញាធរដែនដី។

៣. បទបញ្ជានេះត្រូវបានបកប្រែជាភាសាកម្ពុជា ភាសាឡាវ និងជាភាសាអង់គ្លេស។

៤. ក្នុងដំណើរការអនុវត្តបទបញ្ជានេះ ប្រសិនបើជួបប្រទះនឹងការលំបាក ឬ កើតមានបញ្ហាផ្សេងៗទៀត បណ្តាអង្គភាពពាក់ព័ន្ធត្រូវជូនដំណឹងទៅការិយាល័យតំណាង VRG ប្រចាំនៅប្រទេសដែលអង្គភាពរបស់ខ្លួនកំពុងដំណើរការ ដើម្បីធ្វើការបូកសរុប និង រៀបចំរបាយការណ៍ជូន VRG ពិនិត្យ កែតម្រូវអោយបានត្រឹមត្រូវ និងសមស្រប។

**ប្រធានក្រុមប្រឹក្សាសមាជិក**

(ហត្ថលេខានិងត្រា)

**VO SY LUC**

# ឧបសម្ព័ន្ធទី ១

## បញ្ជីរាយនាមបណ្តាគំរោងអភិវឌ្ឍន៍កៅស៊ូនៃ VRG នៅ ប្រទេសកម្ពុជា

| ល.រ | ឈ្មោះគំរោង | ទីតាំង | ទំហំផ្ទៃដីសម្បទាន (ហត) |
|---|---|---|---|
| ១ | PHU RIENG - KRATIE | ស្រុក ស្នួល ខេត្ត ក្រចេះ | ៨.៣៩៩ |
| ២ | DONG NAI – KRATIE | ស្រុក សំបូរ ខេត្ត ក្រចេះ | ៧.០៩៧ |
| ៣ | DONG PHU – KRATIE | ស្រុក សំបូរ ខេត្ត ក្រចេះ | ៩.៣៩៥ |
| ៤ | VKETI | ស្រុក ស្នួល ខេត្ត ក្រចេះ | ៥.០៥៩ |
| ៥ | DAU TIENG CAMBODIA | ស្រុក ស្នួល ស្រុក ឆ្លូង ខេត្ត ក្រចេះ | ៧.៩៧២ |
| ៦ | DAU TIENG KRATIE | ស្រុក ស្នួល ស្រុក ឆ្លូង ខេត្ត ក្រចេះ | ៦.៥៩២ |
| ៧ | TAN BIEN KAMPONG THOM | ស្រុក សន្ទុក ខេត្ត កំពង់ធំ | ៨.១០០ |
| ៨ | MEKONG | ស្រុក ប្រាសាទ ស្រុក រវាង ខេត្ត ព្រះវិហារ ខេត្ត កំពង់ធំ | ៨.០០០ |
| ៩ | PHUOC HOA – KAMPONG THOM | ស្រុក សន្ទុក ខេត្ត កំពង់ធំ | ៩.១៨៤ |
| ១០ | BA RIA KAMPONG THOM | ស្រុក សន្ទុក ខេត្ត កំពង់ធំ | ៥.៩១៤ |
| ១១ | CRCK II | ស្រុក ស្ទួង ខេត្ត កំពង់ធំ ស្រុក ជីក្រែង ខេត្ត សៀមរាប | ៩.២៣៥ |
| ១២ | BEANHEAK | ស្រុក ប្រាសាទបាលាំង ខេត្ត កំពង់ធំ ស្រុក ជីក្រែង ខេត្ត សៀមរាប | ៩.៤៨០ |
| ១៣ | CRCK | ស្រុក សណ្តាន់ ខេត្ត កំពង់ធំ | ៦.១៥៥ |
| ១៤ | HOANG ANH MANG YANG K | ស្រុក វីនសៃ ខេត្ត រតនគីរី | ៧.១៩៥ |
| ១៥ | KRONG BUK RATTANAKIRI | ស្រុក ឧត្តុងមាស និងស្រុក តាវៀន ខេត្ត រតនគីរី | ៦.៧៦៥ |
| ១៦ | EAH'LEO BM | ស្រុក លំផាត់ ខេត្ត រតនគីរី | ៨.៤០០ |
| ១៧ | CHU PRONG K | ស្រុក ថាឡាបរិវត្ត ខេត្ត ស្ទឹងត្រែង | ៧.៤០០ |
| ១៨ | BINH PHUOC 1 | ស្រុក កែវសីម៉ា ខេត្ត មណ្ឌលគីរី | ៥.១០០ |
| ១៩ | TAY NINH SIEM REAP | ស្រុក ត្រពាំងប្រាសាទ ខេត្ត ឧត្តមានជ័យ | ៧.៦០០ |

## បញ្ជីរាយនាមបណ្តាគំរោងអភិវឌ្ឍន៍កៅស៊ូនៃ VRG នៅ ប្រទេសឡាវ

| ល.រ | ឈ្មោះគំរោង | ទីតាំង | ទំហំផ្ទៃដីសម្បទាន (ហត) |
|---|---|---|---|
| ១ | ក្រុមហ៊ុន VIET LAO | ស្រុក Bachiang ខេត្ត Champasak | ១០.០៦៤ |
| ២ | ក្រុមហ៊ុន QUASACO | ស្រុក Muong Phin និង Se Phon ខេត្ត Savannakhet | ៨.៣៧១ |

# **ឧបសម្ព័ន្ធទី ២**

**ឈ្មោះអង្គភាព** | **ចាងចងនាជាតិ**

លេខ៖........./201...../BN

-------------------------------

ធ្វើនៅ..............ថ្ងៃទី..........ខែ.........ឆ្នាំ............

# **បង្កាន់ដៃទទួលសំណើ ឬ ការតវ៉ា**

**១. ពត៌មានអំពីអង្គភាព**

| | |
|---|---|
| ឈ្មោះអង្គភាព | |
| អាសយដ្ឋាន | |
| លេខទូរសព្ទ | |

**២. ពត៌មានអំពីបុគ្គល ឬ អង្គការមានសំណើ ឬ ការតវ៉ា**

| | |
|---|---|
| ឈ្មោះបុគ្គល ឬ អង្គការ | |
| អាសយដ្ឋាន | |
| លេខទូរសព្ទ | |

**៣. ខ្លឹមសារនៃសំណើ ឬ ការតវ៉ា** (អ្នកទទួលសរសេរដោយសង្ខេប)

.............................................................................................................................

.............................................................................................................................

.............................................................................................................................

.............................................................................................................................

.............................................................................................................................

**៤. ឯកសារបំភ្លឺដែលភ្ជាប់ជាមួយ** ( **ការបញ្ជាក់របស់អ្នកទទួល** )

.............................................................................................................................

.............................................................................................................................

.............................................................................................................................

.............................................................................................................................

**អ្នកទទួល**

(ហត្ថលេខា និងឈ្មោះ)

# ឧបសម្ព័ន្ធទី ៣

## បញ្ជីតាមដានការទទួល និងការដោះស្រាយ លើសំណើ ឬ ការតវ៉ា

| ល.រ | លេខយោង នៃបង្កាន់ដៃ | ថ្ងៃ ខែ ឆ្នាំ ទទួល | ឈ្មោះ អសយដ្ឋាន លេខ ទូរសព្ទរបស់បុគ្គល ឬ អង្គភាព | រូបភាពនៃការ ដាក់សំណើ ឬ ការតវ៉ា | កម្មវត្ថុ នៃសំណើ ឬ ការតវ៉ា | លទ្ធផលនៃការ ដោះស្រាយ | ថ្ងៃឆ្លើយតបដល់ បុគ្គលឬអង្គការមាន សំណើ ឬការតវ៉ា |
|---|---|---|---|---|---|---|---|
| | | | | | | | |
| | | | | | | | |
| | | | | | | | |